# ព្រឹត្តិប័ត្រ អំពី ការបើកសាលា

*ព្រឹត្តិប័ត្រជូនដំណឹងដល់ មាតាបិតា និងសិស្សានុសិស្ស ដែលប៉ះទង្គិច ដោយ ការបិទសាលា ការផ្លាស់ទីកន្លែង និងការបញ្ចូលគ្នា ដើម្បីត្រៀមខ្លួនសម្រាប់ថ្ងៃចូលរៀនដំបូង*



## ការិយាល័យផ្តល់ជំនួយដល់សិស្ស ផ្តល់ការគាំទ្រផ្នែកបញ្ហាខួរក្បាលដល់សិស្សានុសិស្ស នៅក្នុងដំណាក់កាលនៃការផ្លាស់ប្តូរ

ការិយាល័យផ្តល់ជំនួយដល់សិស្ស ខិតខំប្រឹងប្រែងដើម្បីសម្រួលដល់ការផ្លាស់ប្តូរសម្រាប់សិស្សានុសិស្សដែលមានបញ្ហាខួរក្បាល។



គោលបំណងរបស់ការិយាល័យ គឺធ្វើយ៉ាងណាឲ្យសិស្សានុសិស្សដែលបានទទួលជំនួយផ្នែកបញ្ហាខួរក្បាលនៅសាលាដែលត្រូវបិទ នឹងអាចទទួលជំនួយដែលចាំបាច់នៅសាលាថ្មីរបស់ពួកគេ។

អ្នកស្រី Ericka Washington នាយិការង ផ្នែកផ្តល់ចំនួយដល់សិស្ស និងការផ្លាស់ប្តូរ បានមានប្រសាសន៍ថា «ធ្វើដូច្នេះនឹងអាចរក្សាឲ្យការសិក្សា ជាការយកចិត្តទុកដាក់ជាងគេ»

សាលាដែលទទួលសិស្សជាច្រើន នឹងផ្តល់ការព្យាបាលនៅសាលា (STS) ដែលផ្តល់ឲ្យសិស្សានុសិស្ស បឋមសិក្សា និងអនុវិទ្យាល័យ ព្រមទាំងក្រុមគ្រួសារ នូវជំនួយដែលចាំបាច់ដើម្បីជួយដល់ការអភិវឌ្ឍន៍ផ្នែកទំនាក់ទំនងក្នុងសង្គម និងផ្លូវចិត្ត។

### តើយើងធ្វើបានដូចម្តេច?

ចំណុចសំខាន់ៗអំពីការរីកចម្រើនក្នុងការរៀបចំសាលាទទួលសិស្សរបស់ក្រសួង សម្រាប់ឆ្នាំសិក្សាថ្មី៖

**ចំនួនភាគរយ នៃ...**

| | |
|---|---|
| សិស្សានុសិស្សដែលត្រូវការជំនួយអប់រំពិសេស ដែលគេផ្តល់ឱកាសដើម្បីទស្សនាសាលាដែលទទួលសិស្សរបស់ពួកគេ | ១០០% |
| សាលាទទួលសិស្ស ដែលបានទទួលការកែលម្អអាគាររួចរាល់ហើយ | ៥៣% |
| សាលាទទួលសិស្ស ដែលបានបញ្ជាក់ថាមាននាយកសាលានៅឆ្នាំក្រោយ | ៩៦% |
| សិស្ស CTE ដែលគេបានចាត់ឲ្យចូលក្នុងកម្មវិធីដែល ស្រដៀងគ្នា ឬដូចគ្នា | ១០០% |

ការព្យាបាលទាំងនេះគឺជាផ្នែកដ៏សំខាន់នៃថ្ងៃសិក្សា សម្រាប់សិស្សានុសិស្សជាច្រើន មូលហេតុនេះហើយដែលក្រសួងបានខិតខំឲ្យមានការព្យាបាល នៅសាលាដែលទទួលសិស្សមួយចំនួន។

គេផ្តល់ការព្យាបាលនៅសាលា ក្នុងថ្ងៃរៀនធម្មតា រួមទាំងការព្យាបាលសិស្សម្នាក់ៗ និងការព្យាបាលជាក្រុម ព្រមទាំងការធ្វើអន្តរាគមន៍ និងការពិគ្រោះ មួយទល់មួយ ជាមួយបុគ្គលិកផ្នែកសុខភាពខួរក្បាល បានរៀបចំឡើងដើម្បីដោះស្រាយបញ្ហាខួរក្បាល ដែលប៉ះពាល់ដល់សមត្ថភាពសិក្សារបស់ក្មេង ការព្យាបាលនៅសាលា ខិតខំធ្វើឡើងដើម្បីបង្កើតឲ្យមានបរិយាកាសល្អបំផុតសម្រាប់សុខភាពខួរក្បាល។

ការព្យាបាលនៅសាលា បានឧបត្ថម្ភ និងគ្រប់គ្រង ដោយ Community Behavioral Health (CBH) ជាក្រសួងមួយរបស់ក្រុង។ នៅសរទរដូវនេះ ក្រសួងអប់រំនឹង អនុវត្ត និងរក្សា ការព្យាបាលនៅសាលាដែលទទួលសិស្សទាំងនេះ៖ Julia deBurgos, William McKinley, John F. Hartranft, Tilden Middle School, William Dick, W.D. Kelley, E.M. Stanton, Tanner Duckrey, Abigail Vare, Rhodes, Ethel Allen, Morris, Potter Thomas, Penn Treaty, Emlen, Wister, Leeds, Rowen, Pennypacker, Pennell, Wagner, Childs, Arthur, Longstreth, Blankenburg, និង Heston។

ដើម្បីជ្រាបព័ត៌មានបន្ថែមអំពីកម្មវិធីនេះ សូមទូរស័ព្ទមក CBH លេខ ៨៨៨-៥៤៥-២៦០០។

## ដៃគូរបស់ក្រសួងដែលមាន កម្មវិធីសិក្សាក្នុងរដូវក្តៅសម្រាប់សិស្សក្រីក្រ (Springboard Collaborative) ដើម្បីទប់ស្កាត់ការបាត់បង់ការសិក្សានៅរដូវក្តៅ



នៅរដូវក្តៅនេះ ក្រសួងនឹងចាប់ផ្តើមសហការជាមួយ Springboard Collaborative ដើម្បីផ្តល់កម្មវិធីអក្សរសាស្ត្រដល់សិស្សានុសិស្សនៅសាលាបឋមសិក្សាបួន។

ការស្រាវជ្រាវបានឲ្យដឹងថា សិស្សានុសិស្សដែលមានអាយុចូលរៀនថ្នាក់បឋមសិក្សា នៅក្នុងសហគមន៍ដែលមានប្រាក់ចំណូលតិច ជួបប្រទះនូវការបាត់បង់ការរៀនអាននៅរដូវក្តៅ ហើយការសិក្សាមិនបានសម្រេចក្នុងចំណោមសិស្សានុសិស្សវិទ្យាល័យ ភាគច្រើនទាក់ទងនឹងការបាត់បង់ការសិក្សាក្នុងរដូវក្តៅ ក្នុងកំឡុងពេលដែលពួកគេរៀនថ្នាក់បឋមសិក្សា។

គំរូសិក្សារបស់កម្មវិធី Springboard រួមបញ្ចូលការផ្តោតទៅលើការបង្ហាត់បង្រៀនសិស្ស ជាមួយការហ្វឹកហ្វឺនមាតាបិតា ក្នុងប្រព័ន្ធដែលបានរៀបចំឡើងដើម្បីលប់បំបាត់គម្លាតនៃចំណេះដឹងអក្សរសាស្ត្រ នៅពេលដែលសិស្សរៀនដល់ថ្នាក់ទីបួន។ ការទាក់ទាញសិស្សរួមមាន ជំនួយសម្រាប់ការអប់រំ ដូចជា សៀវភៅ និងសម្ភារៈសិក្សាផ្សេងៗ។

កម្មវិធី Springboard នឹងជួយឲ្យសិស្សានុសិស្សមានការរីកចម្រើនបានយូរអង្វែង នូវចំណេះដឹងផ្នែកអក្សរសាស្ត្រ ជំរុញឲ្យមាតាបិតា និងគ្រូ សហការ ហើយជួយបុគ្គលម្នាក់ៗ នៅសាលាដែលបិទ និងនៅសាលាដែលទទួលសិស្ស ឲ្យចាប់ផ្តើមកសាងនូវមនោសញ្ចេតនាជាសហគមន៍ជាថ្មីឡើងវិញ មុនពេលសាលាចាប់ផ្តើមរៀននៅក្នុងខែកញ្ញា។ កម្មវិធី Springboard Collaborative នឹងប្រព្រឹត្តទៅនៅសាលាទាំងនេះ៖

springboard collaborative
teach • train • transform

| សាលា Springboard៖ | ទទួលសិស្សានុសិស្សពីសាលា៖ |
|---|---|
| Blaine Elementary School | L.P. Hill Elementary School |
| Hartranft Elementary School | Ferguson Elementary School |
| McKinley Elementary School | Ferguson Elementary School |
| Duckrey Elementary School | M. Hall Stanton Elementary School |



- **ស្គាល់សាលារបស់កូនលោកអ្នក សម្រាប់ឆ្នាំ ២០១៣-១៤។** សិស្សានុសិស្សទាំងអស់គប្បីបានទទួលលិខិតពីការិយាល័យចុះឈ្មោះ និងចាត់តាំងសិស្ស។ បើសិនជាលោកអ្នកមិនបានទទួលលិខិតនេះទេ សូមទូរស័ព្ទមកលេខ ២១៥-៤០០-៤២៩០។
- **ពិនិត្យមើលប្រក្រតិទិនសាលាសម្រាប់ឆ្នាំក្រោយ។** ប្រក្រតិទិនសម្រាប់ការសិក្សាឆ្នាំក្រោយ ឥឡូវនេះមាននៅក្នុងវិបសៃ www.philasd.org/language/khmer/calendar។ ថ្ងៃទី៩ ខែកញ្ញា គឺជាថ្ងៃ បវេសនកាលដំបូង។
- **សូមចុះឈ្មោះដើម្បីទទួល ព័ត៌មាន និងដំណឹងថ្មីៗ អំពីការផ្លាស់ប្តូរ។** ដើម្បីជ្រាបព័ត៌មានបន្ថែម សូមមើលវិបសៃ www.philasd.org/transitionlistserve ។

- **ការសម្រេចផែនការអំពីយានជំនិះ។** ការិយាល័យផ្តល់យានជំនិះនឹងសម្រេចថាតើសិស្សណាមានសិទ្ធិ ជិះយានជំនិះសាលា និងទទួលប័ណ្ណជិះរថយន្តក្រុង និង SEPTA ដោយយោងទៅលើការតម្រូវរបស់រដ្ឋ និងច្បាប់របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា។ បើសិនជាកូនលោកអ្នកមានសិទ្ធិទទួលការបម្រើផ្នែកយាន្តជំនិះ លោកអ្នកនឹងទទួលលិខិតពីការិយាល័យផ្តល់យានជំនិះ នៅរដូវក្តៅនេះ។
- **រៀបចំសម្រាប់ឯកសណ្ឋានសាលា។** គេតម្រូវឲ្យសិស្សានុសិស្សរបស់ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ាទាំងអស់ ស្លៀកពាក់ឯកសណ្ឋាន។ ដើម្បីមើលច្បាប់សម្រាប់ឯកសណ្ឋានសម្រាប់សាលារបស់កូនលោកអ្នក សូមមើលវិបសៃ www.philasd.org/language/khmer/uniform-code។
- **ចូលរួមក្នុងការជួបជុំគ្នាជាមួយ ក្រុមគ្រួសារ និងការអប់រំ។** សូមចូលរួមជាមួយយើងខ្ញុំ ក្នុងការជួបជុំគ្នាជាមួយ ក្រុមគ្រួសារ និងការអប់រំ នៅថ្ងៃសៅរ៍ ទី១០ ខែសីហា ពីម៉ោង ៨ ព្រឹក ដល់ ៥ ល្ងាច មាន សម្ភារៈចែកជូនដោយឥតគិតថ្លៃ សិក្ខាសាលាអំពីការអប់រំ និងអ្វីៗជាច្រើនទៀត! កម្មវិធីនេះនឹងប្រព្រឹត្តទៅនៅ វិទ្យាល័យ School of the Future អាស័យដ្ឋានលេខ 4021 Parkside Ave.។
- **ចូលរួមក្នុងការដើរមើលសាលា៖** ការិយាល័យទំនាក់ទំនងជាមួយ ក្រុមគ្រួសារ និងសហគមន៍ បានរៀបចំថ្ងៃសម្រាប់ការដើរមើលសាលា សម្រាប់សាលាដែលទទួលសិស្ស នីមួយៗ។ បញ្ជីសម្រាប់ការដើរមើលសាលា នឹងមាននៅក្នុងវិបសៃ ការបើកសាលា នៅពាក់កណ្តាលខែកក្កដា។

## NSBE ផ្តល់កម្មវិធី វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) នៅរដូវក្តៅ

សុំឲ្យសិស្សានុសិស្សថ្នាក់ទីបី ដល់ទីប្រាំ ចូលរួមក្នុង សមាគមវិស្វករនៃជនជាតិស្បែកខ្មៅ- National Society of Black Engineers (NSBE) កម្មវិធីផ្តល់បទពិសោធន៍ផ្នែកវិស្វកម្មនៅរដូវក្តៅ សម្រាប់ក្មេង (SEEK) ដោយឥតគិតថ្លៃ សប្បាយរីករាយ ក្នុងកម្មវិធីវិស្វកម្មបីសប្តាហ៍ នៅសាសាបឋមសិក្សា McDaniel ដែលផ្តោតទៅលើ គណិតវិទ្យា និងវិទ្យាសាស្ត្រ។

អ្នកចូលរួមនឹងរៀនអំពី៖

* STEM (វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និង គណិតវិទ្យា) តាមរយៈការអនុវត្តផ្ទាល់ផ្នែក វិស្វកម្ម។
* និស្សិតមហាវិទ្យាល័យផ្នែក STEM
* តួនាទី និងការទទួលខុសត្រូវរបស់វិស្វករ

ក្នុងសប្តាហ៍នីមួយៗ អ្នកចូលរួមនឹងធ្វើកិច្ចការថ្មី ដែលបញ្ចប់ដោយការបង្ហាញប្លង់រចនា ដែលបានធ្វើរួចចប់សព្វគ្រប់ ដែលអាចអញ្ជើញមាតាបិតាទាំងអស់ឲ្យចូលរួម។

កម្មវិធី SEEK សម្រាប់សិស្សានុសិស្សថ្នាក់ទីបី ដល់ទីប្រាំ នាពេលបច្ចុប្បន្ន។ សាលាបឋមសិក្សា McDaniel ស្ថិតនៅអាស័យដ្ឋានលេខ 1801 S. 22nd St។ ដើម្បីជ្រាបព័ត៌មានបន្ថែម សូមមើលវ៉ិបសៃ www.nsbe.org/seek.aspx ឬទូរស័ព្ទមកលេខ ២១៥-៤០០-៥៨៧២។

NSBE

## លេខដែលគេខ្វស្សាទូរស័ព្ទ

| **បើសិនជាលោកអ្នកមានសំណួរអំពី...** | **លេខទូរស័ព្ទ** |
|---|---|
| **ការបង្កើន និងការគាំទ្រដល់ ការសិក្សា៖** ផ្តល់ការណែនាំ និងការហ្វឹកហ្វឺនផ្នែកការងារដល់គ្រូផ្នែក ដន្ត្រី សិល្បៈ របាំ ល្ខោន កាយវប្បកម្ម ក្រៅម៉ោងសិក្សា កីឡា បណ្ណាល័យ និង ភាសាបរទេស | ២១៥-៤០០-៥៩២០ |
| **វត្តមានអវត្តមាន និងការគេចសាលា៖** ផ្តល់ជំនួយដល់សាលា ដើម្បីកែលម្អវត្តមានអវត្តមាន និងកាត់បន្ថយការគេចសាលា របស់សិស្ស | ២១៥-៤០០-៤២២០ |
| **ការអប់រំអំពី អាជីព និងបច្ចេកវិទ្យា៖** ផ្តល់កម្មវិធី និងជំនួយ សម្រាប់សិស្សានុសិស្ស ដែលបានចូលរួមក្នុងការអប់រំផ្នែក អាជីព និងបច្ចេកវិទ្យា | ២១៥-៤០០-២៣៣១ |
| **ថ្នាក់មុនមត្តេយ្យ៖** ផ្តល់កម្មវិធី និងជំនួយ សម្រាប់ក្មេង ចាប់ពីពេលកើត ដល់អាយុប្រាំមួយឆ្នាំ និងសម្រាប់ក្រុមគ្រួសាររបស់ពួកគេ | ២១៥-៤០០-៤២៧០ |
| **ការចូលរួមរបស់ ក្រុមគ្រួសារ និងសហគមន៍៖** ធ្វើឲ្យក្រុមគ្រួសារ និងសហគមន៍ អាចទាក់ទង និងអាចចូលរួមក្នុងកម្មវិធី និងជំនួយ របស់ក្រសួង | ២១៥-៤០០-៤១៨០ |
| **ការអប់រំផ្នែកភាសាចម្រុះ៖** ផ្តល់ជំនួយ និងការគាំទ្រ ផ្នែកភាសាចម្រុះ ដល់សិស្សានុសិស្ស និងក្រុមគ្រួសារ | ២១៥-៤០០-៤២៤០ |
| **ការចាត់តាំងសិស្ស៖** វាយតម្លៃសំណើសុំផ្លាស់ប្តូរសាលារបស់សិស្ស ហើយសម្រេចការចាត់តាំងសិស្សទៅតាមសាលា | ២១៥-៤០០-៤២៩០ |
| **សំណុំឯកសាររបស់សិស្ស៖** រក្សា និង រៀបចំសំណើសម្រាប់សំណុំឯកសាររបស់សិស្ស (ព្រឹត្តិបត្រពិន្ទុ ការបញ្ជាក់អះអាង ដីកា សំណុំឯកសារសិស្សពិការ ។ល។) | ២១៥-៤០០-៤៧៨០ |
| **ជំនួយពិសេស៖** ផ្តល់ការអប់រំពិសេស ការគាំទ្រពិសេស និងការបម្រើផ្នែកសុខភាពរបស់សិស្ស | ២១៥-៤០០-៤១៧០ |
| **សន្តិសុខរបស់សាលា៖** ចូលរួមជាមួយ រដ្ឋបាលសាលា ប៉ូលីស សិស្សានុសិស្ស មាតាបិតា និងសមាជិកសហគមន៍ ដើម្បីបង្កើនសុវត្ថិភាពរបស់សិស្ស នៅក្នុង និងនៅជុំវិញសាលា | ២១៥-៤០០-៤៧១០ |
| **យានជំនិះ៖** ផ្តល់យានជំនិះដែលមានសុវត្ថិភាពដល់សិស្សានុសិស្ស នៅក្នុងទីក្រុងហ្វីឡាដែលហ្វ្យ៉ា ដែលទៅរៀននៅ សាលារដ្ឋ សាលាឆាធ័រ សាលាសាសនា និង សាលាឯកជន | ២១៥-៤០០-៤៣៥០ |
| **ព័ត៌មានទូទៅ** | ២១៥-៤០០-៤០០០ |


ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា
សូមមើលវ៉ិបសៃរបស់យើងខ្ញុំជាភាសាខ្មែរ
www.philasd.org/language/khmer

មណ្ឌលផ្តល់ជំនួយ
TRANSLATION · interpretation

ខ្សែទូរស័ព្ទសំខាន់ ជាភាសាខ្មែរ
KHMER HOTLINE

២១៥-៤០០-៨៤៨៤